**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន អេលីតវីន (ខេមបូឌា) ឯ.ក**

**កិច្ចព្រមព្រៀងស្ដីអំពីការព្យួរកិច្ចសន្យាការងារ**

កិច្ចព្រមព្រៀងនេះត្រូវបានរៀបចំឡើងរវាង **ក្រុមហ៊ុន អេលីតវីន (ខេមបូឌា) ឯ.ក** ដែលមានអាសយដ្ឋានស្ថិតនៅ ផ្លូវជាតិលេខ៤ ភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល កំណត់ហៅកាត់ថាជាភាគី (ក) និងសហជីពទាំងពីរគឺ សហជីពស្មារតីកម្មករខ្មែរ, សហជីពការងារកម្មករកម្ពុជាដើម្បីប្រជាធិបតេយ្យ និងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន អេលីតវីន (ខេមបូឌា) ឯ.ក កំណត់ហៅកាត់ថាជាភាគី (ខ)។

**ភាគីទាំងពីរបានព្រមព្រៀង និងឯកភាពគ្នាតាមប្រការដូចមានចែងខាងក្រោម៖**

<u>ប្រការ១៖</u> ភាគី (ខ) ឯកភាពអោយភាគី (ក) ដាក់សំណើរសុំព្យួរកិច្ចសន្យាការងាររយៈពេល ០២ខែ ចាប់ពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២០ តាមសេចក្ដីណែនាំលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

<u>ប្រការ២៖</u> ភាគី (ក) យល់ព្រមផ្ដល់ប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លារអាមេរិច ក្នុងមួយខែអោយទៅភាគី (ខ) នៅថ្ងៃទី១០ នៃខែបន្ទាប់ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ។

<u>ប្រការ៣៖</u> ភាគី (ក) និងភាគី (ខ) ព្រមព្រៀងអនុវត្តតាមលក្ខខណ្ឌដូចបានបញ្ជាក់ក្នុងប្រការនីមួយៗខាងលើ និងផ្ដិតស្នាមមេដៃស្ដាំទុកជូនជាភស្ដុតាងតាមផ្លូវច្បាប់។

ថ្ងៃអង្គារ ១កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

កណ្ដាល,ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០

**នាយកក្រុមហ៊ុន ភាគី (ក)** **ស្នាមមេដៃស្ដាំ សហជីពទាំងពីរ និងប្រតិភូបុគ្គលិក ភាគី (ខ)**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អេលីតវីន (ខេមបូឌា) ឯ.ក H/R KINGDOM OF CAMBODIA